# ឧបករណ៍តន្ត្រី "គងវង់"

ពាក្យ "គង" ជាលក្ខណៈនៃក្រុមទាំងមូល សំដៅទៅលើឧបករណ៍គ្រឿងដំ រួមមាន គងញី (គងដោះ) គងឈ្មោល (គងរាបឬគងសំប៉ែត) គងតូច គងធំ គងវង់តូច និងគងវង់ធំ។[១] "គងវង់" សំដៅលើគងតូចនិងគងធំ មានដើមកំណើតនិងអភិវឌ្ឍន៍មកពីឧបករណ៍តន្ត្រី "ពាទ្យ" ដែលមានរូបចម្លាក់ឆ្លាក់នៅលើជញ្ជាំងប្រាសាទអង្គរវត្ត (ថែវខាងជើង) នាសតវត្សទី១២។ ឧបករណ៍ពាទ្យ ជាឧបករណ៍តន្ត្រីដើមដែលផ្តល់កំណើតនិងអភិវឌ្ឍន៍ដល់គងតូចនិងគងធំប្រើនៅក្នុងវង់តន្ត្រីពិណពាទ្យសព្វថ្ងៃ។

គងវង់តូច មានផ្ទៃ១៨និងគងវង់ធំ មានផ្ទៃ១៦ ប្រើនៅក្នុងវង់តន្ត្រីពិណពាទ្យ ដែលរួមជាមួយនឹងឧបករណ៍តន្ត្រីឯទៀត មានស្រឡៃ រនាតឯក រនាតដែក រនាតធុង សម្ភោរ ស្គរធំ និងឈឹង។ គេរៀបផ្ទៃគងតូចនិងគងធំពីឆ្វេងទៅស្តាំ ពីសូរទាបទៅខ្ពស់ នៅក្នុងរង្វង់រាងមូលធ្វើពីផ្តៅដំបង។ គេចងផ្ទៃគងនីមួយៗដោយប្រើចម្រៀកស្បែកគោ ធ្វើជាខ្សែភ្ជាប់ទៅនឹងរង្វង់គងដែលធ្វើពីផ្តៅនោះ។

ផ្ទៃគងមានរាងដូចផ្តិលនិងមានដោះប៉ោងឡើងនៅចំកណ្តាលផ្ទៃ ជាកន្លែងដែលអ្នកលេងវាយនឹងអន្លូង។ គេសិតផ្ទៃគងពីសំរិទ្ធលាយនឹងលង្ហិន។ អន្លូងគងធ្វើពីស្បែកដំរី ឬស្បែកក្របី កាត់ជាថាសមូលតូចហើយចោះរន្ធនៅចំកណ្តាលដើម្បីស៊កដងធ្វើពីឈើសម្រាប់អ្នកលេងកាន់វាយគង។ ដើម្បីឱ្យត្រូវសូរដែលចង់បាន គេធៀបផ្ទៃគងដោយប្រើប្រមរបិទនៅក្នុងដោះគងនោះ។

ផ្ទៃគងតូច មានទំហំប្រមាណ ១៣,៥០ស.ម. - ១៤ស.ម.

---

[១] ខ្មែរយើងធ្លាប់មានគងវង់មួយប្រភេទទៀតហៅថា "គងវង់ធុង" ១៦ផ្ទៃមានសូរទាបជាងនិងទំហំធំជាង គងវង់ធំ ដែលគេលេងដូចរនាតធុងដែរ។ គងវង់ធុងនេះ គេឃើញមាននៅក្នុងព្រះបរមរាជវាំងភ្នំពេញ រហូតដល់ទសវត្ស១៩៦០។ បច្ចុប្បន្ននេះ យើងមិនឃើញមានគងវង់ធុងប្រើនៅក្នុងវង់តន្ត្រីទៀតឡើយ (កែវ ២០១១: ១០២)។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ផ្ទៃគងធំ មានទំហំប្រមាណ ១៦,៥០ស.ម. - ១៨,៥០ស.ម.

ផ្ទៃគងតូច មានទំហំប្រមាណ ២០ស.ម. - ២២ស.ម.[២]

ការបាត់បង់ឬឈប់ប្រើគងវង់តូចនៅកម្ពុជា ជារឿងមួយដែលយើងសោកស្តាយពេក ណាស់។ នេះជាកត្តាមួយដែលយើងអាចយកជាឧទាហរណ៍ថា បើយើងមិនប្រើវាទេ យើងនឹងបាត់បង់កេរដំណែលដូនតាខ្មែរ ដែលជាកាតព្វកិច្ចរបស់យើងត្រូវថែរក្សា។ ក៏ដូចជាទម្រង់សិល្បៈមួយចំនួនដែលបានបាត់បង់មួយរយៈដែរ ដោយសារស្មារតី ការយកចិត្តទុកដាក់និងការខិតខំប្រឹងប្រែងរបស់យើង យើងបានធ្វើឲ្យទម្រង់ទាំងនោះបានរស់រានមានជីវិតឡើងវិញ មានជាអាទិ៍៖ ល្ខោនអាប៉េ ល្ខោនប្រាមោជ្ជទ័យ ល្ខោនពោលស្រី ល្ខោនគៃន ល្ខោនក្ងោកការ ល្ខោនស្បែកពណ៌ និងឧបករណ៍តន្ត្រីពិណ ជាដើម។ល។

[២] កែវ ២០១១: ១០២

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

## ឯកសារពិគ្រោះ

កែវ ណារុំ

២០១១. *តន្ត្រីនៅប្រទេសខ្មែរ*. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។

ជួន ណាត

១៩៦៧. *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ពេជ្រ ទុំក្រវិល

២០០៣. *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

Aymonier, Etienne

1878. *Dictionnaire Khmer- Français*. Saigon: n.p.

Guesdon, Joseph

1930. *Dictionnaire Cambodgien-Français*, 2 vols. Paris: Librairie d'Amérique et d'Orient, I-II.

Janneau, Gustav Jean Auguste

1870. *Manuel Pratique*. Saigon: Imprimerie Impériale.

*Musique Khmère*

1969. Phnom Penh: Imprimerie Sangkum Réastr Niyum.

Sam, Sam-Ang

1988. *The Pin Peat Ensemble: Its Fundamental, Music, and Context*. Ph.D. dissertation, Wesleyan University.

________. (2002). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION